Education
Public Schools

Safe Bus Travel




# ព័ត៌មានអំពីសុវត្ថិភាពតាមដងផ្លូវ

លោកអ្នកទទួលខុសត្រូវចំពោះសុវត្ថិភាពរបស់កូនលោកអ្នក នៅពេលកូនលោកអ្នកធ្វើដំណើរទៅកាន់និងវិលត្រឡប់ពីសាលារៀន។

# ដំណើរតាមរថយន្តក្រុងប្រកបដោយសុវត្ថិភាព

កុមារអាចមានគ្រោះថ្នាក់បំផុតបន្ទាប់ពីចេញពីរថយន្តក្រុងភ្លាមមួយរំពេច។

**ដើម្បីកាត់បន្ថយគ្រោះថ្នាក់៖**

- រង់ចាំជួបកូនលោកអ្នកនៅកន្លែងរថយន្តក្រុងឈប់ – កុំចាំជួបនៅឯទីម្ខាងទៀតនៃដងផ្លូវឱ្យសោះ
- កាន់ដៃកូនលោកអ្នកនៅកន្លែងរថយន្តក្រុងឈប់
- ឈរចម្ងាយពីរបីជំហានពីមាត់ចិញ្ចើមផ្លូវ នៅពេលចាំកូននៅកន្លែងរថយន្តក្រុងឈប់
- រង់ចាំរហូតទាល់តែរថយន្តក្រុងបានបើកចេញទៅ បន្ទាប់មកជ្រើសយកកន្លែងមួយដែលមានសុវត្ថិភាពដើម្បីឆ្លងផ្លូវ។

**ជួយកូនលោកអ្នកក្នុងការរកកន្លែងមានសុវត្ថិភាពដើម្បីឆ្លងផ្លូវ ដូចជា៖**

- នៅកន្លែងឆ្លងផ្លូវសម្រាប់អ្នកថ្មើរជើង ឬកន្លែងភ្លើងស្តុប បើសិនជាមាន
- កន្លែងណាមួយនៅតាមដងផ្លូវដែលអ្នកបើកបរទាំងអស់អាចមើលឃើញច្បាស់។

បើលោកអ្នកមិនអាចទៅចាំទទួលកូនលោកអ្នកបានទេ សូមរៀបចំឱ្យជនពេញវ័យណាម្នាក់ដែលលោកអ្នកទុកចិត្ត ទៅទទួលយកកូនលោកអ្នកនៅកន្លែងរថយន្តក្រុងឈប់។




**ដើម្បីទទួលជំនួយបន្ថែម**

សូមអានកម្មវិធីអប់រំអំពីសុវត្ថិភាពនៅតាមផ្លូវរបស់ក្រសួង នៅឯ https://education.nsw.gov.au/road-safety-education ឬបើកមើល https://education.nsw.gov.au ហើយស្វែងរកមើលការអប់រំអំពីសុវត្ថិភាពនៅតាមផ្លូវ។